សុវត្ថិភាពសម្រាប់ពេលជិះរថយន្តដឹកសិស្ស

# រថយន្តដឹកសិស្ស។ ឈប់។




The Children's Hospital *of* Philadelphia®

Hope lives here.

# ក្មេងភាគច្រើនដែលមានរបួសដោយរថយន្តដឹកសិស្ស គឺមិនមែននៅពេលជិះទេ គឺនៅពេលដែលពួកគេនៅក្រៅ ឬនៅជិតរថយន្ត ដែលអ្នកបើករថយន្តមើលពួកគេមិនឃើញ។

## សុវត្ថិភាពបំផុតក្នុងការដើរឆ្លងផ្លូវ:

- វិន័យដើរឆ្លងផ្លូវ: មើលឆ្វេង បន្ទាប់មកមើលស្តាំ បន្ទាប់មកមើលឆ្វេងម្តងទៀត។
- តែងតែដើរឆ្លងផ្លូវនៅត្រង់កន្លែងកាច់ជ្រុង តាមផ្លូវដើរឆ្លង។
- មិនត្រូវដើរឆ្លងផ្លូវនៅចន្លោះឡានចត។

## នៅកន្លែងរថយន្តដឹកសិស្សឈប់:

- ត្រូវទៅដល់កន្លែងចាំរថយន្តដឹកសិស្សយ៉ាងហោចណាស់ប្រាំនាទីមុន ធ្វើដូច្នេះដើម្បីកុំឲ្យអ្នកមានការប្រញាប់ប្រញាល់។
- ចាំរហូតដល់រថយន្តដឹកសិស្សឈប់ស្រួលបួល បើកទ្វារ ហើយបើកភ្លើងក្រហមសុវត្ថិភាពភ្លឹបភ្លែតៗ។
- មើលឲ្យច្បាស់កុំឲ្យមានអ្វីអូសអន្ទែអន្ទាយ ដែលអាចទាក់ទ្វាររថយន្ត។
- បើអ្នកធ្វើធ្លាក់របស់អ្វីមួយនៅជិត ឬនៅក្រោមរថយន្តដឹកសិស្ស កុំតាមរើសវា។ ជួសមកវិញ ត្រូវប្រាប់អ្នកបើករថយន្ត។
- កុំឈរនៅលើថ្នល់ចាំរថយន្តដឹកសិស្ស។

## មុនពេលចុះពីរថយន្តដឹកសិស្ស:

- មើលឲ្យច្បាស់កុំឲ្យមានអ្វីលានចេញពីសំពៀតសៀវភៅរបស់អ្នក ដែលអាចទាក់នឹងបង្កាន់ដៃ។
- មុនពេលចុះពីរថយន្តដឹកសិស្ស មើលឡានសិន ហើយមើលឲ្យច្បាស់ថាឡាននោះឈប់។
- មើលឲ្យច្បាស់ថាអ្នកបើករថយន្តដឹកសិស្សមើលអ្នកឃើញ មុនពេលអ្នកដើរឆ្លងផ្លូវ។ អ្នកបើករថយន្តភាគច្រើននឹងប្រាប់អ្នកឲ្យដឹង នៅពេលដើរទៅបាន។
- ត្រូវដឹងនូវបរិវេណដែលនាំឲ្យមានគ្រោះថ្នាក់: ១០ ហ្វីត ជុំវិញរថយន្ត។ អ្នកបើករថយន្តមិនអាចមើលអ្នកឃើញទេ នៅក្នុងបរិវេណដែលនាំឲ្យមានគ្រោះថ្នាក់។

កម្មវិធីការពារមិនឲ្យមានរបួស Kohl
(Kohl's Injury Prevention Program)

The Children's Hospital *of* Philadelphia®

Hope lives here.

©2011 មន្ទីរពេទ្យកុមារក្រុងហ្វីឡាដែលហ្វៀ (The Children's Hospital of Philadelphia) រក្សាសិទ្ធិគ្រប់យ៉ាង។ 4721/NP/04-11

សម្រាប់ព័ត៌មានបន្ថែមអំពីការរក្សាសុវត្ថិភាពកូនរបស់អ្នក និងពិធីផ្សេងៗទៀតសម្រាប់ក្រុមគ្រួសារ សូមមើល www.chop.edu/childsafety.

KOHL'S Cares®
Committed to Kids' Health and Education